# ធ្វើផែនការមួយសម្រាប់ការបោះឆ្នោតដោយជោគជ័យ!

នេះគឺជារឿងសំខាន់មួយចំនួនដែលត្រូវគិត នៅមុនពេលបោះឆ្នោតម្ដងៗ ដើម្បីជួយធានាបានថាអ្នកទទួលបានបទពិសោធន៍បោះឆ្នោតដ៏ជោគជ័យ។ អ្នកអាចសរសេរផែនការបោះឆ្នោតផ្ទាល់ខ្លួនអ្នកនៅលើបីទំព័របន្ទាប់។ អ្នកអាចជ្រើសរើសចែករំលែកផែនការរបស់អ្នកទៅដល់អ្នកផ្សេងទៀតដែលគាំទ្រដល់អ្នក ប៉ុន្តែអ្នកមិនចាំបាច់ត្រូវចែករំលែកផែនការនេះក៏បាន។

ប្រសិនបើអ្នកមានសំណួរណាមួយ អ្នកអាចទាក់ទងទៅកាន់ការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នក ឬអ្នកអាចទូរសព្ទទៅកាន់លេខទូរសព្ទបន្ទាន់សម្រាប់ការបោះឆ្នោតរបស់ Rights California៖ (888) 569-7955។

**ការចុះឈ្មោះបោះឆ្នោត៖** អ្នកត្រូវតែចុះឈ្មោះ ទើបអាចបោះឆ្នោតបាន។

- តើអ្នកបានចុះឈ្មោះបោះឆ្នោតដែរឬទេ?
- តើឈ្មោះនិងអាសយដ្ឋានរបស់អ្នកបានធ្វើបច្ចុប្បន្នភាពនៅក្នុងការចុះឈ្មោះបោះឆ្នោតរបស់អ្នកដែរឬទេ?
- ប្រសិនបើអ្នកនៅក្រោមអនុបាលភាព តើតុលាការបានចេញសេចក្ដីបង្គាប់មិនឲ្យអ្នកទៅបោះឆ្នោតដែរឬទេ?

**ការបោះឆ្នោតតាមសំបុត្រ៖** សន្លឹកឆ្នោតនឹងត្រូវបានផ្ញើទៅកាន់អ្នកបោះឆ្នោតសកម្មដែលបានចុះឈ្មោះ។

- តើអ្នកចង់បោះឆ្នោតតាមសំបុត្រដែរឬទេ?
- តើអ្នកអាចគូស និង/ឬកាន់ក្រដាសសន្លឹកឆ្នោតចុះឡើងបានដែរឬទេ?
- តើអ្នកត្រូវការចង់បានឯកសារបោះឆ្នោតរបស់អ្នកជាទម្រង់ផ្សេងទៀតដែរឬទេ?
- ប្រសិនបើអ្នកចង់ប្រើប្រព័ន្ធបោះឆ្នោតតាមសំបុត្រដែលអាចចូលបោះបានពីចម្ងាយ (RAVBM) ជំនួសវិញ តើអ្នកមានបច្ចេកវិទ្យាដែលអ្នកត្រូវការដែរឬទេ?
- តើអ្នកអាចចុះឈ្មោះរបស់អ្នកបានដែរឬទេ? ប្រសិនបើទេ តើអ្នកដឹងអំពីជម្រើសរបស់អ្នកដែរឬទេ?
- តើអ្នកអាចប្រគល់សន្លឹកឆ្នោតដែលបានគូសរួចរបស់ខ្លួនបានទាន់ពេលវេលាតាមសំបុត្រប្រៃសណីយ៍ នៅក្នុងហិបទម្លាក់សន្លឹកឆ្នោត ឬដោយផ្ទាល់នៅទីតាំងបោះឆ្នោតបានដែរឬទេ?
- តើអ្នកត្រូវការជំនួយលើកិច្ចការពាក់ព័ន្ធនឹងការបោះឆ្នោតដែរឬទេ? ប្រសិនបើត្រូវការ តើនរណានឹងជួយអ្នក ជួយដោយរបៀបណា និងនៅពេលណា? តើអ្នកមានផែនការបម្រុងទុកដែរឬទេ?

**ការបោះឆ្នោតដោយផ្ទាល់៖** ទោះបីសន្លឹកឆ្នោតត្រូវបានផ្ញើហើយក៏ដោយ ក៏អ្នកនៅតែអាចបោះឆ្នោតដោយផ្ទាល់បានផងដែរ។

គន្លឹះរៀបចំផែនការបោះឆ្នោតពី Disability Rights California ខែសីហា ឆ្នាំ2022
**លេខទូរសព្ទបន្ទាន់សម្រាប់ការបោះឆ្នោត៖ (888) 569-7955**

- តើអ្នកត្រូវការ (ឬចូលចិត្ត) បោះឆ្នោតដោយផ្ទាល់ដែរឬទេ?
- តើអាសយដ្ឋាននៃទីតាំងបោះឆ្នោតកន្លែងណាដែលអ្នកនឹងប្រើប្រាស់?
- តើនៅថ្ងៃណា និងម៉ោងប៉ុន្មានដែលទីតាំងបោះឆ្នោត បើកដំណើរការ?
- តើអ្នកមានមធ្យោបាយណាមួយដើម្បីទៅកាន់ទីតាំងបោះឆ្នោតដែរឬទេ?
- តើអ្នកដឹងអំពីជម្រើសដែលអាចចូលទៅបោះឆ្នោតបាន ដែលមានផ្តល់ជូននៅទីនោះដែរឬទេ?
- តើអ្នកត្រូវការជំនួយលើកិច្ចការពាក់ព័ន្ធនឹងការបោះឆ្នោតដែរឬទេ? ប្រសិនបើត្រូវការ តើមានមនុស្សម្នាក់ឬពីរនាក់ដែលអ្នកចង់សុំឲ្យទៅជាមួយអ្នកទៅកាន់ទីតាំងបោះឆ្នោតដែរឬទេ? តើពួកគេទំនេរដែរឬទេ?

# ផែនការបោះឆ្នោតរបស់ខ្ញុំ

ថ្ងៃបោះឆ្នោត៖ ______________

សេចក្តីណែនាំ៖ គូសធីកលើប្រអប់ដែលត្រឹមត្រូវសម្រាប់អ្នក។ ប្រសិនបើអ្នកមិនដឹងអំពីអ្វីមួយ ឬមិនដឹងពីរបៀបគូសវានោះទេ អ្នកអាចទាក់ទងទៅកាន់ការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នក អ្នកអាចទូរសព្ទទៅកាន់លេខទូរសព្ទបន្ទាន់សម្រាប់ការបោះឆ្នោតរបស់ Disability Rights California តាមរយៈលេខ (888) 569-7955 ឬអ្នកអាចសុំនរណាម្នាក់ផ្សេងទៀតដែលអ្នកជឿទុកចិត្តឲ្យជួយអ្នកបាន។ ការគិតទុកជាមុន នឹងជួយអ្នកឲ្យបានដឹងពីចន្លោះប្រហោងនៅក្នុងផែនការរបស់អ្នក និងដោះស្រាយបញ្ហាចន្លោះប្រហោងទាំងនោះនៅមុនថ្ងៃបោះឆ្នោត។

## ការចុះឈ្មោះបោះឆ្នោត

☐ ខ្ញុំបានចុះឈ្មោះបោះឆ្នោត។
☐ ការិយាល័យបោះឆ្នោតប្រចាំខោនធី មានឈ្មោះនិងអាសយដ្ឋានបច្ចុប្បន្នរបស់ខ្ញុំ។
☐ ខ្ញុំមិនទាន់បានចុះឈ្មោះបោះឆ្នោតនៅឡើយទេ ប៉ុន្តែខ្ញុំដឹងថាត្រូវអនុវត្តជំហានណាខ្លះដើម្បីចុះឈ្មោះ។
☐ ខ្ញុំមិនទាន់បានចុះឈ្មោះបោះឆ្នោតនៅឡើយទេ ហើយខ្ញុំត្រូវការជំនួយក្នុងការស្វែងយល់ពីរបៀបចុះឈ្មោះ។

## ការបោះឆ្នោតតាមសំបុត្រ

☐ ខ្ញុំធ្វើផែនការបោះឆ្នោតតាមសំបុត្រ។
☐ ខ្ញុំអាចគូសលើក្រដាសសន្លឹកឆ្នោតដែលបានផ្ញើមកឲ្យខ្ញុំ។
☐ ខ្ញុំត្រូវការឯកសារបោះឆ្នោតរបស់ខ្ញុំជាទម្រង់ជំនួសផ្សេងទៀតមួយឬច្រើន។
  ☐ ខ្ញុំបានស្នើសុំទម្រង់(នានា)ខាងក្រោមពីការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់ខ្ញុំ។
  ☐ ខ្ញុំបានស្នើសុំទម្រង់(នានា)ខាងក្រោមពីរដ្ឋលេខាធិការនៃរដ្ឋកាលីហ្វ័រញ៉ា។
  ទម្រង់(នានា)៖☐ អក្សរពុម្ពធំ ☐ ឯកសារជាសំឡេង ☐ អក្សរស្ទាប ☐ PDF
☐ ខ្ញុំធ្វើផែនការប្រើប្រាស់ប្រព័ន្ធបោះឆ្នោតតាមសំបុត្រដែលអាចចូលបោះបានពីចម្ងាយ (RAVBM) ដើម្បីគូសសន្លឹកឆ្នោតរបស់ខ្ញុំដោយប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកណាមួយ។
  ☐ ខ្ញុំមានលទ្ធភាពទទួលបានរាល់បច្ចេកវិទ្យាទាំងអស់ដែលខ្ញុំត្រូវការដើម្បីប្រើប្រាស់ប្រព័ន្ធ RAVBM។
    ☐ កុំព្យូទ័រ ឬទូរសព្ទស្មាតហ្វូនដែលមានអ៊ីនធឺណិតប្រើប្រាស់។
    ☐ ម៉ាស៊ីនព្រីនដែលបានភ្ជាប់ទៅកាន់កុំព្យូទ័រ ឬទូរសព្ទស្មាតហ្វូន។

☐ ខ្ញុំអាចអាន និងកាន់ក្រដាសសន្លឹកឆ្នោតប្រព័ន្ធ RAVBM បានក្រោយពេលខ្ញុំព្រីនវាចេញមក។

☐ ខ្ញុំបានចុះឈ្មោះដើម្បីប្រើប្រាស់ប្រព័ន្ធ RAVBM ប្រចាំខោនធីរបស់ខ្ញុំ។

☐ ខ្ញុំបានអនុវត្តប្រើប្រាស់ប្រព័ន្ធ RAVBM ដោយប្រើគេហទំព័រណែនាំបង្ហាញ។

☐ ខ្ញុំដឹងពីរបៀបដែលខ្ញុំនឹងត្រូវចុះហត្ថលេខាលើស្រោមសំបុត្រប្រគល់សន្លឹកឆ្នោតត្រឡប់វិញ (មធ្យោបាយណាមួយខាងក្រោម)។

☐ ខ្ញុំអាចចុះហត្ថលេខាលើឈ្មោះរបស់ខ្ញុំ ហើយហត្ថលេខារបស់ខ្ញុំគួរតែដូចគ្នាជាមួយនឹងហត្ថលេខាដែលការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់ខ្ញុំមាននៅលើហ្វាល់ឯកសារសម្រាប់ខ្ញុំ។

☐ ខ្ញុំមិនអាចចុះហត្ថលេខាលើឈ្មោះរបស់ខ្ញុំបានទេ ដូច្នេះខ្ញុំនឹងប្រើសញ្ញាដូចជា X ជំនួសឲ្យឈ្មោះរបស់ខ្ញុំ ហើយខ្ញុំនឹងឲ្យនរណាម្នាក់ចុះហត្ថលេខាជាសាក្សីលើស្រោមសំបុត្រ។

☐ ខ្ញុំនឹងប្រើប្រាស់ត្រាហត្ថលេខាដែលខ្ញុំបានចុះហត្ថលេខាទុកជាមុន។

☐ ខ្ញុំធ្វើផែនការប្រគល់សន្លឹកឆ្នោតដែលបានគូសរួចរបស់ខ្ញុំ ដូចខាងក្រោម៖

☐ តាមសំបុត្រប្រៃសណីយ៍ (បានវាយត្រាប្រៃសណីយ៍នៅថ្ងៃ ឬមុនថ្ងៃបោះឆ្នោត)

☐ នៅក្នុងហិបទម្លាក់សន្លឹកឆ្នោត (មិនឲ្យហួសម៉ោង 8:00 យប់នៅថ្ងៃបោះឆ្នោត)

ទីតាំងហិបទម្លាក់សន្លឹកឆ្នោត៖ ____________________

☐ នៅទីតាំងបោះឆ្នោត (មិនឲ្យហួសម៉ោង 8:00 យប់នៅថ្ងៃបោះឆ្នោត)

ទីតាំងបោះឆ្នោត៖ ____________________

## ការបោះឆ្នោតដោយផ្ទាល់

☐ ខ្ញុំធ្វើផែនការបោះឆ្នោតដោយផ្ទាល់។

☐ ខ្ញុំធ្វើផែនការបោះឆ្នោតនៅទីតាំងនេះ៖ ____________________

☐ ការបោះឆ្នោតដោយផ្ទាល់មុនពេលកំណត់ (មុនថ្ងៃបោះឆ្នោត) គឺមានផ្តល់ជូននៅទីតាំងនេះ។

☐ ខ្ញុំធ្វើផែនការបោះឆ្នោតនៅថ្ងៃនេះ៖ ____________________

☐ ទីតាំងបោះឆ្នោតនឹងបើកដំណើរការនៅម៉ោងទាំងនេះ៖ ____________

☐ ផែនការរបស់ខ្ញុំសម្រាប់ការទៅដល់ទីតាំងបោះឆ្នោតគឺ ____________

____________________________________________

☐ ខ្ញុំបានពិនិត្យមើលក្តីបារម្ភណាមួយដែលខ្ញុំមានអំពីលទ្ធភាពចេញចូលបានដោយផ្ទាល់ទៅកាន់ទីតាំងបោះឆ្នោត។

☐ ខ្ញុំចង់ប្រើប្រាស់ការបោះឆ្នោតនៅតាមចិញ្ចើមផ្លូវ។

☐ ខ្ញុំបានបញ្ជាក់ថា វាមានផ្តល់ជូននៅទីតាំងបោះឆ្នោតរបស់ខ្ញុំ។

☐ ខ្ញុំនឹងពីរបៀបទូរសព្ទទៅកាន់បុគ្គលិកបោះឆ្នោតឲ្យមកកាន់យានយន្តរបស់ខ្ញុំ នៅពេលខ្ញុំមកដល់។

☐ ខ្ញុំធ្វើផែនការប្រើប្រាស់អ្វីមួយដូចខាងក្រោម ដែលនឹងជួយខ្ញុំឲ្យបោះឆ្នោតដោយផ្ទាល់បាន៖

- ☐ ម៉ាស៊ីនបោះឆ្នោតដែលអាចចូលប្រើប្រាស់បាន (ហៅផងដែរថា ឧបករណ៍គូសសន្លឹកឆ្នោត) មានមុខងារប្រើប្រាស់កម្មវិធីជាពិសេសដូចខាងក្រោម៖
  - ☐ ថាច់ស្ក្រីន
  - ☐ ឯកសារជាសំឡេងដែលអានអត្ថបទនៅលើអេក្រង់ និងផ្តល់ការណែនាំ
  - ☐ ពង្រីកអក្សរនៅលើអេក្រង់
  - ☐ ផ្លាស់ប្តូរពណ៌ពន្លឺនៅលើអេក្រង់
  - ☐ រន្ធដោតសម្រាប់ភ្ជាប់ឧបករណ៍ “sip-and-puff” ឬ “paddle switch”
- ☐ ផ្ទាំងឬកែវពង្រីក
- ☐ ដុំមូលសម្រាប់ចាប់កាន់ប៊ិច (ដើម្បីជួយអ្នកក្នុងការកាន់ប៊ិច)
- ☐ ចន្លោះបំពេញហត្ថលេខា (ដើម្បីជួយអ្នកឲ្យចុះហត្ថលេខាលើទីតាំងត្រឹមត្រូវ)

☐ បុគ្គល/មនុស្សដូចខាងក្រោមនេះ នឹងចូលទៅកាន់ទីតាំងបោះឆ្នោតជាមួយខ្ញុំ៖

1. ______________________________________________
2. ______________________________________________

**ជំនួយក្នុងការបោះឆ្នោត**

សេចក្តីណែនាំ៖ អ្នកអាចប្រើប្រាស់ទំព័រនេះដើម្បីកត់ត្រាកំណត់ចំណាំផ្សេងទៀតណាមួយពីកិច្ចដំណើរការរៀបចំផែនការរបស់អ្នក។ តើជំនួយអ្វីខ្លះដែលអ្នកចង់បាន ឬត្រូវការ ដើម្បីឲ្យអ្នកអាចបោះឆ្នោតបានដោយជោគជ័យ? គិតអំពីលទ្ធភាពចូលទៅបោះឆ្នោតពីដើមដល់ចប់៖ ចាប់ពីការចុះឈ្មោះបោះឆ្នោត ដើម្បីស្វែងយល់ពីអ្វីដែលមាននៅលើសន្លឹកឆ្នោត រហូតដល់ការបោះឆ្នោតរបស់អ្នក។

☐ ខ្ញុំត្រូវការជំនួយលើកិច្ចការពាក់ព័ន្ធនឹងការបោះឆ្នោតដូចខាងក្រោម៖

☐ បុគ្គល/មនុស្សដូចខាងក្រោមនេះ បានយល់ព្រមជួយខ្ញុំ៖

☐ នេះគឺជាព័ត៍មានលម្អិតអំពីរបៀបនិងពេលវេលាដែលខ្ញុំនឹងទទួលបានជំនួយនេះ៖

☐ ប្រសិនបើផែនការខាងលើមិនដំណើរការទេ ផែនការបម្រុងរបស់ខ្ញុំគឺមានដូចខាងក្រោម៖